**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: ០៧៣/១៥ ក.អ.ជ.ប្រក

ថ្ងៃ សុក្រ ៧កើត ខែពិសាខ ឆ្នាំមមែ ព.ស.២៥៥៩

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មេសា គ.ស ២០១៥

# ប្រកាស

## ស្តីពី

## ការកែសម្រួលសមាសភាពមន្ត្រីរាជការបម្រើការងារជាមួយគម្រោងស្តារឡើងវិញបន្ទាន់នូវហេដ្ឋារចនាសម្ព័ន្ធរបវ័ន្តខូចខាតដោយទឹកជំនន់ឆ្នាំ ២០១៣ ក្នុងក្របខណ្ឌឥណទានធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងជំនួយឥតសំណងរបស់រដ្ឋាភិបាលអូស្ត្រាលី (AusAID)

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១២ ស្តីពីការដាក់ឱ្យប្រើប្រាស់នូវនីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍
- យោងប្រកាសលេខ ១០២/១៤ ក.អ.ជ.ប្រក ចុះថ្ងៃទី ០២ ខែមេសា គ.ស ២០១៤ ស្តីពីការបង្កើត និងតែងតាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការបម្រើការងារជាមួយគម្រោងស្តារឡើងវិញបន្ទាន់នូវហេដ្ឋារចនាសម្ព័ន្ធរបវ័ន្តខូចខាតដោយទឹកជំនន់ឆ្នាំ ២០១៣ ក្នុងក្របខណ្ឌឥណទានធនាគារអភិវឌ្ឍន៍អាស៊ី និងជំនួយឥតសំណងរបស់រដ្ឋាភិបាលអូស្ត្រាលី
- យោងលិខិតលេខ ១១០ សហវ ចុះថ្ងៃទី ០៦ ខែមករា ឆ្នាំ ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងលិខិតលេខ ០៤៣ សហវ ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**ប្រការ ១.-** តែងតាំងមន្ត្រីរាជការសម្រាប់បម្រើការងារគម្រោងស្តារឡើងវិញបន្ទាន់នូវហេដ្ឋារចនាសម្ព័ន្ធរបវ័ន្តខូចខាតដោយទឹកជំនន់ឆ្នាំ ២០១៣ ដែលមានសមាសភាពដូចខាងក្រោម÷



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

**ក. អង្គភាពអនុវត្តន៍គម្រោង**

១. លោក **ឆួច សំណាង** ជាអ្នកគ្រប់គ្រងគម្រោង ជំនួសលោក **ង៉ោ ដូ** ដែលបានទទួលមរណភាព។

**ខ. ខេត្តសៀមរាប**

១. លោក **ស៊ីច រដ្ឋា** ជាអ្នកសម្របសម្រួលគម្រោងខេត្តសៀមរាប ជំនួសលោក **ហេង សុខអេង** ដែលត្រូវបានទទួលភារកិច្ចថ្មី។

**គ. ខេត្តបាត់ដំបង**

១. លោក **ហែម សុវណ្ណា** ជាអ្នកសម្របសម្រួលគម្រោងខេត្តបាត់ដំបង ជំនួសលោក **ស៊ីច រដ្ឋា** ដែលត្រូវបានទទួលភារកិច្ចថ្មី។

២. លោក **សេង សុខុម** ជាមន្ត្រីបច្ចេកទេសគម្រោងខេត្តបាត់ដំបង ជំនួសលោក **ឈួន ឃុន** ។

**ប្រការ ២.-** សេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៣.-** នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ ប្រធាននាយកដ្ឋានពាក់ព័ន្ធ គ្រប់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តពាក់ព័ន្ធ និងសាមីខ្លួនដូចមានក្នុងប្រការ ១ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជា សុផារ៉ា

<u>**កន្លែងទទួល**</u>

*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*
*-មន្ទីរពាក់ព័ន្ធ*
*"ដើម្បីជូនជ្រាប"*
*-ដូចប្រការ៣*
*"ដើម្បីអនុវត្ត"*
*-ឯកសារ - កាលប្បវត្តិ*



Download